# ការតម្លើងកម្មវិធីដាក់ក្នុងទូរសព្ទ iPhone<br>KH Taurus តាមទូរសព្ទដៃ<br>វិធីសាស្រ្តតម្លើងកម្មវិធី

**KH Taurus Mobile**-គឺជាកម្មវិធីដែលបង្កើតឡើងសម្រាប់រង្វាយតម្លៃការផ្សំចំណីសម្រាប់គោសាច់នៅកម្ពុជា ដែលអាចប្រើជាមួយទូរសព្ទដៃ ជាភាសាអង់គ្លេស និងជាភាសាខ្មែរបាន។

## តម្រូវការរបស់ប្រព័ន្ធ

មុនពេលតម្លើងកម្មវិធី ត្រូវប្រាកដថាទូរសព្ទរបស់អ្នកត្រូវបំពេញតាមតម្រូវការដូចខាងក្រោម។ សម្រាប់ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌនៃការតម្លើងកម្មវិធី សូមចូលទៅកាន់គេហទំព័រខាងក្រោម៖ https://geosoftware.faculty.ucdavis.edu/resources/

- **កម្មវិធីគ្រប់គ្រងឯកសារ (File Manager)** – អ្នកត្រូវការកម្មវិធីគ្រប់គ្រងឯកសារដើម្បីជាកន្លែងសម្រាប់ស្តុកទុកឯកសារដែលបានទាញយករួច។ សម្រាប់ទូរសព្ទ iOS មានកម្មវិធីគ្រប់គ្រងឯកសារផ្ទាល់ខ្លួនរួចជាស្រេច។ ប៉ុន្តែសម្រាប់ទូរស័ព្ទ Android អ្នកត្រូវការតំឡើងកម្មវិធីគ្រប់គ្រងឯកសារមួយផ្សេងទៀត។ កម្មវិធីគ្រប់គ្រងឯកសារឥតគិតថ្លៃល្អបំផុតគឺកម្មវិធីគ្រប់គ្រងឯកសារពីកម្មវិធី ASD Dev Video Player for All Format ដែលកម្មវិធីនេះអាចប្រើប្រាស់បានជាមួយវីដេអូគ្រប់ទម្រង់។
- **កម្មវិធី Google Docs** – កម្មវិធីទូរសព្ទរបស់យើងបង្កើតរបាយការណ៍ក្នុងទម្រង់ជា Rich Text (RTF) ហើយអ្នកត្រូវការកម្មវិធីពិនិត្យមើល RTF នៅលើទូរសព្ទរបស់អ្នក។ កម្មវិធីមើល RTF ឥតគិតថ្លៃល្អបំផុតគឺ Google Docs ។
- **ពុម្ពអក្សរ (Fonts)** – ដើម្បីមើលរបាយការណ៍ជាភាសាខ្មែរ អ្នកត្រូវតែតម្លើងពុម្ពអក្សរខ្មែរនៅលើទូរសព្ទរបស់អ្នក។
- **កម្មវិធី Google Gmail** – កម្មវិធីទូរសព្ទរបស់យើងផ្ញើរបាយការណ៍ដែលបានបង្កើតរួចជាឯកសារភ្ជាប់នៅក្នុងអ៊ីមែល ហើយអ្នកត្រូវមានកម្មវិធីអ៊ីមែលនៅលើទូរសព្ទរបស់អ្នក។ កម្មវិធីអ៊ីមែលឥតគិតថ្លៃល្អបំផុតគឺ Google Gmail ។
- កម្មវិធី **Google Chrome** – ដើម្បីប្រើ Google Docs និង Google Gmail ដោយមិនប្រើប្រាស់អ៊ីនធើ ណែត អ្នកត្រូវការកម្មវិធី Google Chrome នៅលើទូរសព្ទរបស់អ្នក។

## ការតម្លើងកម្មវិធី

ការប្រុងប្រយ័ត្ន – ប្រសិនបើអ្នកមានទម្រង់ចាស់នៃកម្មវិធី Taurus Mobile នៅលើទូរសព្ទ iPhone របស់អ្នក សូមលុបវាចោល មុនពេលតម្លើងកម្មវិធីថ្មីមួយនេះ។

មុននឹងដាក់ឱ្យប្រើប្រាស់កម្មវិធី iOS ជាសាធារណៈនៅលើ App Store យើងត្រូវដាក់ពង្រាយកម្មវិធីទាំងនេះទៅកាន់ក្រុមមនុស្សដែលមានចំនួនកំណត់សម្រាប់ការសាកល្បង។ ដើម្បីធ្វើវាបាន យើងត្រូវប្រើវិធីសាស្រ្ត Ad Hoc ហើយដាក់ឱ្យប្រើប្រាស់តាមអ៊ីនធើណែត។

1. នៅលើទូរសព្ទ iPhone របស់អ្នក សូមចុចលើកម្មវិធីរុករកបណ្តាញ Safari រួចចូលទៅកាន់គេហទំព័រកម្មវិធី GEO៖ https://GEOSoftware.faculty.ucdavis.edu




2. រុករកទៅទំព័រក្នុងការទាញយក (Download page )

3. រំកិលចុះក្រោមទៅផ្នែក iOS
4. រំកិលលចុះក្រោមទៅកាន់ Taurus Monile សម្រាប់ប្រទេសកម្ពុជា ហើយចុចលើតំណ InstallOnAir




5. អេក្រង់ខាងក្រោមលេចឡើង។ ចុចលើប៊ូតុង **Click here** ដើម្បីតម្លើង




6. អេក្រង់ខាងក្រោមលេចឡើង រួចចុចលើប៊ូតុង **Install** ។




7. អេក្រង់មួយទៀតនឹងបង្ហាញ នូវសារដែលទាក់ទងទៅនឹងការតម្លើង។




8. សារ "ការតម្លើង" នេះមិនដែលបញ្ចប់ទេ ហើយប្រព័ន្ធក៏មិនបានចង្អុលបង្ហាញថា ការតម្លើងត្រូវបានបញ្ចប់នោះទេ។ នេះគឺជាលក្ខណ:ច្របូកច្របល់នៃវិធីសាស្ត្រនេះ។ អ្នកគិតថាការតម្លើងត្រូវបានបរាជ័យ។ ប៉ុន្តែផ្ទុយទៅវិញ កម្មវិធីនេះត្រូវបានតម្លើងនៅលើទូរស័ព្ទរបស់អ្នករួចស្រេច។

9. រង់ចាំពីរបីនាទី បន្ទាប់មករកមើលរូបតំណាងកម្មវិធី (app icon) នៅលើទូរសព្ទ iPhone របស់អ្នកដូចបានបង្ហាញខាងក្រោម:




**10.** ប្រសិនបើអ្នកមិនបានផ្ញើរ UDID នៃទូរសព្ទ iPhone របស់អ្នកមកយើងទេ អ្នកនឹងទទួលបានសារកំហុសមួយនៅជាប់នឹងរូបតំណាងរបស់ Taurus ដូចដែលបានបង្ហាញខាងក្រោម។ សូមធ្វើតាមការណែនាំនៅក្នុងសៀវភៅណែនាំ UDID ហើយផ្ញើ UDID របស់អ្នកមកយើង ហើយយើងនឹងបន្ថែម ទូរសព្ទ iPhoneរបស់អ្នកទៅក្នុងបញ្ជីរបស់យើង។




### របៀបបើកដំណើរការ

1. នៅពេលដែលកម្មវិធីត្រូវបានដំឡើងនៅលើទូរសព្ទ iPhone របស់អ្នក សូមចុចរូបតំណាងរបស់កម្មវិធី (app icon) ។ វានឹងលោតសារដាស់តឿន ដែលស្នើរឱ្យអ្នកបើកដំណើរការ Developer Mode។ រួចចុចប៊ូតុង OK ។
2. ចូលទៅកាន់ Settings រួចចូលទៅកាន់ Privacy & Security > Developer Mode
3. ចូលទៅកាន់ការកំណត់ Developer Mode
4. ចុចលើប៊ូតុងបិទបើក។ អ្នកនឹងទទួលបានសារពី iOS ដើម្បីចាប់ផ្តើមដំណើរការឡើងវិញនូវម៉ាស៊ីនទូរសព្ទ (Device) របស់អ្នក។ រួចចុចលើប៊ូតុង Restart ។
5. បន្ទាប់ពីម៉ាស៊ីនទូរសព្ទចាប់ផ្តើមឡើងវិញ សូមដោះសោម៉ាស៊ីនទូរសព្ទរបស់អ្នក។ ការជូនដំណឹងពីប្រព័ន្ធនឹងលេចឡើង។ ចុចបើក ហើយបន្ទាប់មក បញ្ចូលលេខកូដសម្ងាត់ម៉ាស៊ីនទូរសព្ទរបស់អ្នក។
6. នោះ Developer Mode នឹងត្រូវបានបើកដំណើរការបាន។ ពេលនេះអ្នកអាចធ្វើអន្តរកម្មទំហំផ្ទុកខាងក្នុងជាមួយម៉ាស៊ីនទូរសព្ទ និងការបង្កើតដើម្បីរក្សាទុកក្នុងម៉ាស៊ីនទូរសព្ទរបស់អ្នក។

អ្នកអាចបិទ Developer Mode នៅពេលណាក៏បាន ប៉ុន្តែត្រូវចំណាំថាអ្នកនឹងត្រូវធ្វើតាមដំណើរការដដែលនេះម្តងទៀតដើម្បីបើកវាឡើងវិញ។

តំណភ្ជាប់ទៅកាន់វីដេអូនៃការបង្រៀនបើកប្រើប្រាស់ Developer Mode នៅក្នុង YouTube

https://www.youtube.com/watch?v=HfZuVFfqruc